ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

## មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ

# របាយការណ៍

# សិក្ខាសាលាស្តីពី “ការគ្រប់គ្រង និងអនុវត្តន៍កម្មវិធីបង្ការ និង ថែទាំជំងឺអេដស៍ និងអ្នកជំងឺកាមរោគសំរាប់ថ្នាក់ស្រុកប្រតិបត្តិ” មន្ទីរសុខាភិបាល ខេត្តតាកែវ

## Workshop on HIV/AIDS and STI Project Implementation and Management at Operational District Level

**តាកែវ, ថ្ងៃទី ២៤-២៦ ខែ វិច្ឆិកា ឆ្នាំ ២០១០**

រៀបចំដោយ　　　　　　　　ឧបត្ថម្ភដោយ

**GFATM 7**

# របាយការណ៍សិក្ខាសាលា ស្តីពីការងារគ្រប់គ្រង និងអនុវត្ត កម្មវិធីបង្ការ ថែទាំជំងឺអេដស៍ និងជំងឺកាមរោគ នៅមន្ទីរសុខាភិបាល ខេត្តតាកែវ

**១-កាលបរិច្ឆេទ** : ពីថ្ងៃទី ២៤ - ២៦ ខែ វិច្ឆិកា ឆ្នាំ ២០១០

**២-ទីកន្លែង** : សាលប្រជុំមន្ទីរសុខាភិបាលខេត្ត តាកែវ

**៣-ឧបត្ថម្ភដោយ** : មូលនិធិសកលជុំទី ៧

**៤-រៀបចំដោយ** : ផ្នែកផែនការ តាមដាន និងវាយតំលៃ នៃមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ

**៥-គោលបំណងនៃសិក្ខាសាលា :**

- ផ្តល់ការយល់ដឹងពីមុខងារ និងតួនាទីរបស់មន្ត្រីនៅស្រុកប្រតិបត្តិក្នុងការការងារគ្រប់គ្រង និងការពង្រឹងការយល់ដឹងក្នុងការអនុវត្ត ដល់មន្ត្រីសំរបសំរួល និងបុគ្គលិកថ្នាក់ស្រុកប្រតិបត្តិ ដោយផ្អែកលើផែនការយុទ្ធសាស្ត្រសំរាប់កម្មវិធីបង្ការ ថែទាំជំងឺអេដស៍ និងកាមរោគ នៅក្នុងវិស័យសុខាភិបាល ។
- ផ្តល់ចំណេះដឹង និងជំនាញដល់មន្ត្រីស្រុកប្រតិបត្តិ និងអ្នកសំរបសំរួល ដើម្បីមានលទ្ធភាពរៀបចំផែនការសកម្មភាពគ្រប់ជ្រុងជ្រោយ និងរបាយការណ៍ប្រចាំត្រីមាស និងប្រចាំឆ្នាំ សំរាប់ថ្នាក់ស្រុកប្រតិបត្តិ ។
- ពង្រឹងយន្តការលើការសំរបសំរួល និងកិច្ចសហប្រតិបត្តិការជាមួយ និងបុគ្គលិកសុខាភិបាលនៅតាមសហគមន៍ សេវាសុខភាព ដៃគូ និងម្ចាស់ជំនួយ ។
- ផ្តល់ជាជំនួយនៅក្នុងការអនុវត្តន៏គំរោងអោយបានប្រសើរឡើង ដោយផ្អែកលើផែនការសកម្មភាព និងប្រចាំត្រីមាស ព្រមទាំងស្វែងយល់ពីការងារសំរបសំរួល ដោយរៀបចំជាកិច្ចព្រមព្រៀងជាមួយដៃគូ និងម្ចាស់ជំនួយដែលពាក់ព័ន្ធនិងកម្មវិធីបង្ការ ថែទាំ ព្យាបាលជំងឺអេដស៍ និងជំងឺកាមរោគនៅស្រុកប្រតិបត្តិ ។

**សមាសភាពចូលរួម :**

មានសិក្ខាកាមចូលរួមចំនួន ៤៨ រូប មកពីខេត្តចំនួន ០៩ និង ១៥ ស្រុកប្រតិបត្តិ ដែលមានមន្ត្រីសំខាន់ចំនួន ៣ រូបនោះមាន លោកប្រធានស្រុកប្រតិបត្តិ អនុប្រធាន និងមន្ត្រីសំរបសំរួលស្រុកប្រតិបត្តិថ្នាក់ស្រុកប្រតិបត្តិមកពីខេត្តពោធិសាត់ ( បាកាន មាន ០៤ នាក់ ) ក្រុងកំពត ( អង្គរជ័យមាន ០២ នាក់ និង ជ្រុគមាន ០២ នាក់ ) ខេត្តស្វាយរៀង (ជីភូមាន ០២ នាក់ ខេត្តកំពង់ចាមមាន ០១ នាក់) ខេត្តព្រៃវែង ( មាន ០២ នាក់ ) ខេត្តសៀមរាប អង្គរជុំមាន ០២ នាក់ ខេត្តកំពង់ឆ្នាំង មាន ០៦ នាក់ និង ខេត្តតាកែវមានចំនួន ១០ នាក់ ដែលមកពីស្រុកប្រតិបត្តិ ០៦ នាក់ អ្នកសំរបសំរួល ០៣ នាក់ និងអ្នកបើក និងបិទកម្មវិធី ចំនួន ០១ នាក់ ព្រមទាំងមន្ត្រីផ្នែកជំនាញមកពីមជ្ឈមណ្ឌលជាតិ ប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគមានចំនួន ១៥ នាក់ រួមទាំងអ្នកបើកបរចំនួន ០២ នាក់ ។

**៦.សកម្មភាព :**

**ថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០១០**

**ពេលព្រឹក:**

មតិចំណាប់អារម្មណ៏របស់លោកវេជ្ជបណ្ឌិត **គីម ប៊ុណ្ណា** បានបញ្ជាក់ពីគោលបំណងនៃសិក្ខាសាលាដែលមានសារៈសំខាន់ក្នុងការផ្តល់ការយល់ដឹងពីការងារគ្រប់គ្រង និងអនុវត្តកម្មវិធីបង្ការ ថែទាំជំងឺអេដស៍ និងកាមរោគ និងការស្វែងយល់ពីតួនាទី មុខងាររបស់មន្ត្រីសុខាភិបាលថ្នាក់ស្រុកប្រតិបត្តិ និងផ្តល់ការយល់ដឹងបន្ថែមពីការរៀបចំបណ្តាញទំនាក់ទំនងគ្នារវាងការផ្តល់សេវានានា ដូចជាសេវាថែទាំ និងព្យាបាលនៅគ្រឹះស្ថានសុខាភិបាល សេវាថែទាំនៅតាមសហគមន៍ដើម្បីធានាអោយអ្នកជំងឺអេដស៍ អាចទទួលបាននូវគ្រប់សេវាទាំងអស់ទៅតាមតំរូវការ។ រហូតមកដល់បច្ចុប្បន្ននេះចំនួនសរុបអ្នកផ្ទុកមេរោគអេដស៍មាន ៤១៦៦៩ នាក់ ដែលក្នុងនោះមានកុមារចំនួន ៤00១ នាក់ មនុស្សពេញវ័យ និងមនុស្សចាស់មានចំនួន ៣៧៦៦៨ នាក់។

មតិសំណេះសំណាល និងការប្រកាសបើកសិក្ខាសាលានេះ ដោយវេជ្ជបណ្ឌិត **នុត ស៊ីណាត** អនុប្រធានមន្ទីរសុខាភិបាលខេត្តតាកែវ ដោយលោកបានសម្តែងនូវការកោតសរសើរចំពោះកិច្ចខំប្រឹងប្រែងយកចិត្តទុកដាក់ ចំពោះលោក-លោកស្រី ដែលរួមគ្នាអនុវត្តសកម្មភាពទាំងអស់កន្លងមក។ ខេត្តតាកែវមានប្រជាជនប្រមាណជាង ៩ សែន នាក់ និងមានស្រុកប្រតិបត្តិចំនួន ៧៦ នាក់។ មានស្រុកប្រតិបត្តិចំនួន 0៥ កំពុងអនុវត្តន៍ SOA ទាំងអស់ដោយស្រុកប្រតិបត្តិធ្វើកិច្ចសន្យាជាមួយមន្ទីរ ដើម្បីអនុវត្តសកម្មភាព ហើយវគ្គសិក្ខាសាលានេះមានសារៈសំខាន់ចំពោះការគ្រប់គ្រង និងអនុវត្តកម្មវិធីបង្ការ និងថែទាំជំងឺអេដស៍-ជំងឺកាមរោគ សំរាប់មន្ត្រីថ្នាក់ស្រុកប្រតិបត្តិ។ ចំពោះសកម្មភាព Link Response និងមាន Site សំរាប់ផ្តល់សេវា OI/ARV។ លោកអនុប្រធានបានបន្ថែមទៀតថា តាងនាមអោយខេត្តតាកែវសូមថ្លែងអំណរគុណចំពោះឯកឧត្តមវេជ្ជបណ្ឌិត **មាន ឈីវុន** ប្រធានមជ្ឈមណ្ឌលជាតិ ប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ ដែលតែងតែគាំទ្រចំពោះរាល់សកម្មភាពទាំងអស់ ដែលអនុវត្តន៏កម្មវិធីប្រកបដោយភាពជោគជ័យ។

បន្ទាប់មកមន្ត្រីជំនាញនៃមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគបានបង្ហាញពីការងារសំខាន់ៗ ដូចដែលបានបញ្ជាក់នៅក្នុងកាលវិភាគខាងក្រោម:

- ការបង្ហាញពីការគោលបំណងនៃសិក្ខាសាលា តួនាទី និងមុខងាររបស់មន្ត្រីសុខាភិបាលស្រុកប្រតិបត្តិ ផែនការយុទ្ធសាស្ត្រ និងទិសដៅឆ្នាំ ២០១១-២០១៥ ដោយលោកវេជ្ជ. **គិម ប៊ុណ្ណា** ព្រមទាំងមានសំនួរ និងចំលើយ។

**ពេលរសៀល:**

- ការបង្ហាញពីយុទ្ធសាស្ត្រ ( Link Response ) នៅស្រុកប្រតិបត្តិ ដែលមាន CoC និងបង្ហាញយុទ្ធសាស្ត្ររបេង អេដស៍ (3 Is) និងការអនុវត្តសកម្មភាពបង្ការ ការចំលងមេរោគអេដស៍ចំពោះអ្នកផ្ទុកមេរោគអេដស៍ (Positive Prevention ) នៅស្រុកប្រតិបត្តិ ដោយលោក វេជ្ជ. **សេង វុធី**។

- ការបង្ហាញពីការអនុវត្តសកម្មភាពបង្ការ ថែទាំ និងគាំទ្រ សំរាប់អ្នកផ្ទុកមេរោគអេដស៍នៅតាមសហគមន៍ ដោយលោកវេជ្ជ. **សេង វុធី**។

- ការបង្ហាញពីនិតិវិធីក្នុងការប្រើប្រាស់ ការគ្រប់គ្រងថវិកា គំរោងឧបត្ថម្ភតាមរយៈមជ្ឈមណ្ឌលជាតិ និងបង្ហាញពីប្រព័ន្ធរបាយការណ៍គណនេយ្យ និងលំហូរថវិកា សំរាប់ឧបត្ថម្ភដល់ការអនុវត្តកម្មវិធីអេដស៍ នៅតាមស្រុកប្រតិបត្តិដោយតំណាងផ្នែកហិរញ្ញកិច្ច នៃមជ្ឈមណ្ឌលជាតិ ។

- ការបង្ហាញពីទំរង់ និងបែបបទសំរាប់ការលើកផែនការសកម្មភាព ទិសដៅ ថវិកាលំអិត និងមានការពិភាក្សារួមដោយលោកវេជ្ជ. **ឆ្លង់ សុវណ្ណនា** ។

**ថ្ងៃ ទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០១០**

**<u>ពេលព្រឹក:</u>**

- ការគ្រប់គ្រងទិន្នន័យ និងទំរង់របាយការណ៍សំរាប់កម្មវិធីជំងឺអេដស៍ និងជំងឺកាមរោគដោយលោក **ចាត់ វ៉ាសនា** ។
- ការតាមដាន និងប្រព័ន្ធរបាយការណ៍ដោយលោកវេជ្ជ.**ឆ្លង់ សុវណ្ណនា** ។

**<u>ពេលរសៀល</u>**

- ការវិភាគអំពីស្ថានភាព និងការឆ្លើយតបទៅនឹងការរាលដាលមេរោគអេដស៍ នៅស្រុកប្រតិបត្តិ និងពិភាក្សាជាក្រុម និងករណីសិក្សាដោយលោកវេជ្ជ. **តឹម ប៊ុណ្ណា** ។

- ការវិភាគពីស្ថានភាពទាក់ទងនឹងការឆ្លងមេរោគអេដស៍ នៅក្នុងស្រុកប្រតិបត្តិ ( ចំនុចខ្លាំង និងចំនុចខ្សោយ) ការរៀបចំផែនការសកម្មភាព ទិសដៅ ការគ្រប់គ្រង និងរៀបចំរបាយការណ៍ដោយលោកស្រីវេជ្ជ. **ផុនលី និមល** ។

**ថ្ងៃ ទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០១០**

**<u>ពេលព្រឹក:</u>**

- ការបង្ហាញពីលទ្ធផលរបស់ក្រុមពិភាក្សាដោយលោកវេជ្ជ. **តឹម ប៊ុណ្ណា** ។

**<u>ពេលរសៀល</u>**

- ការបង្ហាញពីលទ្ធផលរបស់ក្រុមពិភាក្សា ដោយក្រុមនិមួយៗ មានពិភាក្សាទូទៅ និងបិទអង្គសិក្ខាសាលាដោយលោកវេជ្ជ. **តឹម ប៊ុណ្ណា** ។

## ៧.របាយតំលៃវគ្គកិច្ចប្រជុំ :

### ៧.១. ចំណុចល្អ :

- មានកិច្ចស្វាគមន៍យ៉ាងកក់ក្ដៅ និងផ្ដល់អនុសាស្រ្តល្អៗ ពីអនុប្រធានមន្ទីរសុខាភិបាលខេត្ត
- មន្ទីរសុខាភិបាលខេត្ត ផ្ដល់ទីកន្លែងសំរាប់ដំណើរការកិច្ចប្រជុំបានយ៉ាងល្អ ។
- មានការពិភាក្សាគ្នា ដោយមានការសហការរវាងអ្នកចូលរួម និងអ្នកសំរបសំរួលក្នុងអង្គសិក្ខាសាលានេះ ។
- មានការបង្ហាញអំពីកាលវិភាគ ការគ្រប់គ្រង និងអនុវត្តកម្មវិធីបង្ការ និងថែទាំជំងឺអេដស៍-ជំងឺកាមរោគ សំរាប់មន្ត្រីថ្នាក់ស្រុកប្រតិបត្តិ ដោយមានឯកសារជា (Hard Copies and Soft Copies)។

## ៧.២. បញ្ហា និង ដំណោះស្រាយ :

| សំនួរ | ដំណោះស្រាយ |
|---|---|
| ១.ចំពោះគូស្វាមី និងភរិយា ដោយភរិយាជាអ្នកផ្ទុកមេរោគអេដស៏ តើស្វាមីអាចមានផ្ទុកមេរោគដែររឺទេ? | - ចំពោះបញ្ហានេះមិនមានកើតទេ បើសិនមានការប្រើប្រាស់ស្រោមអនាម័យអោយបានត្រឹមត្រូវ ។ |
| ២.ចំពោះបុរសម្នាក់បានទៅធ្វើតេស្តរកមេរោគអេសដ៏ឃើញនូវលទ្ធផលវិជ្ជមាននៅមន្ទីរសុខាភិបាល ប៉ុន្តែគាត់ទៅពិនិត្យនៅគ្លីនិកដទៃទៀតឃើញលទ្ធផលអវិជ្ជមាន បើសិនជាមានបញ្ហាបែបនេះ តើមជ្ឈ-មណ្ឌលជាតិមានវិធានការណ៍យ៉ាងដូចម្តេច? | -ត្រូវមានការពន្យល់ណែនាំគាត់ឱ្យបានត្រឹមត្រូវដោយអោយគាត់ធ្វើតេស្តឈាមរកមេរោគអេដស៏ អោយបានច្រើនដងដើម្បីអោយដឹងច្បាស់ពីលទ្ធផលជាក់ស្តែង ។ |
| ៣.ចំពោះអ្នកជំងឺរបេង និងផ្ទុកមេរោគអេដស៏ តើត្រូវទៅយកថ្នាំនៅកន្លែងណាចំពោះស្រុកប្រតិបត្តិព្រះស្តេច ។ | -ចំពោះអ្នកជំងឺអេដស៏ ដែលត្រូវទទួលថ្នាំ OI/ARV មិនមែនទទួលតែមួយដងទេ តែត្រូវទទួលបានមួយជីវិត ។ ដូច្នេះត្រូវបង្កើន Site បន្ថែមដើម្បីទទួលយកសេវានេះ ដោយមានថវិកាគ្រប់គ្រាន់ ហើយអ្នកជំងឺត្រូវទៅពិនិត្យនៅអ្នកលឿង ។ |
| ៤.ទាក់ទងនឹងរបាយការណ៏ មានការលំបាកចំពោះ Link Response ដោយមានផ្នែកជាច្រើនពាក់ព័ន្ធ គ្នា ហើយការបញ្ចូលមានបញ្ហា Error មួយចំនួនចំពោះខេត្តពោធិសាត់ ។ | -ទាក់ទងនឹងរឿងនេះ តែងតែមានបញ្ហាមួយចំនួនខ្លះ ប៉ុន្តែយើងត្រូវធ្វើឱ្យសុក្រិត និងទំនាក់ទំនងបន្ថែមចំពោះកន្លែងដែល Error ។ |
| ៥.ចំពោះរបាយការណ៏នៃ Link Respose តើត្រូវបំពេញយ៉ាងម៉េច? | -របាយការណ៏នេះខាងខេត្ត ត្រូវផ្ញើមកមជ្ឈមណ្ឌលជាតិនៅពេលដែលបំពេញរួច ហើយ NCHADS មាន Form មួយទៀត ដើម្បីបញ្ចូលក្នុងទិន្នន័យ ។ |
| ៦.ពាក់ព័ន្ធសកម្មភាពតាមគំរោងផែនការ នៃការចំណាយ តើយើងគួរបន្ថែមរឺយ៉ាងម៉េច? | -ត្រូវធ្វើផែនការដើម្បីទុកសំរាប់ស្រុកប្រតិបត្តិ ទោះបីជាសកម្មភាពនេះ មិនមានយ៉ាងណាក៏ដោយ ។ |

**៨_សំណូមពរ :**

- សូមអោយមជ្ឈមណ្ឌលជាតិបង្កើតរចនាសម្ព័ន្ធអោយបានត្រឹមត្រូវ និងបញ្ជាក់ច្បាស់លាស់ពីតួនាទី ដើម្បីងាយស្រួលដល់ស្រុកប្រតិបត្តិ និងកុំអោយខុសពីការអនុវត្តន៍របស់ស្រុកប្រតិបត្តិ ។
- ចំពោះរចនាសម្ព័ន្ធសំរាប់កម្មវិធីជំងឺអេដស៍ និងកាមរោគខេត្ត ដែលមានស្រុកប្រតិបត្តិ សំរាប់ដាក់អោយអនុវត្តន៍សិន ប៉ុន្តែមិនទាន់ចុះហត្ថលេខា ពីក្រសួងសុខាភិបាលនៅឡើយ ។

សិក្ខាសាលានេះបានបញ្ចប់នៅថ្ងៃទី ២៦ ខែវិច្ឆិកា ឆ្នាំ ២០១០ វេលាម៉ោង ៥ : ០០ នាទី ដោយមានការពិភាក្សា និងផ្តល់អនុសាសន៍ដោយវេជ្ជបណ្ឌិតតំណាង **មជ្ឈមណ្ឌលជាតិ** បានផ្តល់ការណែនាំ និងដំណោះស្រាយទៅនឹងបញ្ហាផ្សេងៗ ដែលបានលើកឡើងនៅក្នុងសិក្ខាសាលានេះ ព្រមទាំងឆ្លើយតបទៅនឹងសំណូមពរដូចដែលបានរៀបរាប់ខាងលើ និងមានការសំណេះសំណាលផ្តាំផ្ញើ និងប្រកាសបិទកិច្ចប្រជុំ ។

ថ្ងៃទី ២៦ ខែវិច្ឆិកា ឆ្នាំ ២០១០

អ្នកធ្វើរបាយការណ៍

កញ្ញា រស់ សុវណ្ណារ៉ា

**បានឃើញ និង ឯកភាព**

**ប្រធានមជ្ឈមណ្ឌលជាតិ**

**វេជ្ជ. មាន_ឈីវុន**